# ការវិនិយោគដ៏ល្អបំផុត

អែលឌើរ ឆេលដុន អែហ្វ ឆាល
នៃក្រុមពួក 70 នាក់

បើអ្នកបង់ដង្វាយមួយភាគក្នុងដប់ ដោយស្មោះត្រង់ជានិច្ច នោះព្រះអម្ចាស់នឹងប្រទានពរដល់អ្នក។ វានឹងក្លាយទៅជាការវិនិយោគដ៏ល្អបំផុតដែលអ្នកមិនដែលធ្លាប់ធ្វើ។

កាលខ្ញុំនៅក្មេង អ្នកជិតខាងម្នាក់របស់យើងមានហ្វូងគោមួយហ្វូងចិញ្ចឹមយកទឹកដោះលក់។ គោមួយក្បាលរបស់គាត់បានងាប់ដែលបន្សល់នូវកូនគោទើបនឹងកើតមួយក្បាល គាត់បានឱ្យកូនគោនោះមកខ្ញុំ។ ខ្ញុំបានចិញ្ចឹមកូនគោនោះឱ្យធំណើវា និងថែទាំវា។ នៅថ្ងៃដែលលោកប៉ារបស់ខ្ញុំយកវាទៅកន្លែងកាប់គោដើម្បីលក់ គឺជាថ្ងៃមួយដែលខ្ញុំមានអារម្មណ៏ច្របូកច្របល់ណាស់ៈ ខ្ញុំស្រឡាញ់កូនគោរបស់ខ្ញុំ ប៉ុន្តែខ្ញុំក៏ទន្ទឹងចង់បានទូវរង្វាន់ ដែលមកពីកម្លាំងពលកម្មរបស់ខ្ញុំផងដែរ។ សំណើរតែមួយរបស់ខ្ញុំគឺថាប្រាក់ ដែលខ្ញុំទទួលបានមកពីការលក់កូនគោនោះ គឺសុំជាកាក់ប្រាក់ដុល្លារ។ ខ្ញុំចងចាំថា ពេលលោកប៉ាត្រឡប់មកផ្ទះវិញនៅយប់នោះ គាត់បានដាក់កាក់ប្រាក់ 20 ដុល្លារមកក្នុងដៃរបស់ខ្ញុំ។ ប្រាក់នោះពិបាករកបានណាស់ ហើយខ្ញុំគិតថាខ្ញុំមានប្រាក់ទាំងអស់នៅក្នុងពិភពលោកនេះ។ ខ្ញុំបានរាប់ប្រាក់នោះ កោតសរសើរនិងខាត់កាក់នីមួយៗដោយយកចិត្តទុកដាក់។ នៅពេលថ្ងៃអាទិត្យមកដល់ ខ្ញុំបានដាក់កាក់ប្រាក់ភ្លឺពីរកាក់ដោយស្ទាក់ស្ទើរចូលក្នុងហោប៉ៅរបស់ខ្ញុំ ដើម្បីបង់ដង្វាយមួយភាគក្នុងដប់របស់ខ្ញុំ។ វាក៏ពិបាកដែលមានកាក់ប្រាក់ដុល្លារមានតម្លៃនៅក្នុងខ្លួនប្រគល់ទៅឱ្យប៊ីស្សពផងដែរ ប៉ុន្តែឥឡូវនេះខ្ញុំនៅចាំអំពីអារម្មណ៏យ៉ាងល្អដែលខ្ញុំមាននៅពេលគោរពតាមព្រះអម្ចាស់ ។

នៅតាមផ្លូវចេញមកពីព្រះវិហារទៅកាន់ផ្ទះ ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថាគាត់មានមោទនភាពចំពោះខ្ញុំណាស់។ រួចគាត់និយាយថា "ជីតារបស់កូនតែងតែប្រាប់យើងជាកូនចៅថា បើយើងបង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់ប្រកបដោយសេចក្តីជំនឿ នោះព្រះអម្ចាស់នឹងប្រទានពរដល់យើង ហើយវានឹងក្លាយទៅជាការវិនិយោគដ៏ល្អបំផុតដែលយើងអាចធ្វើ"។

ជីតារបស់ខ្ញុំយល់ដឹងថា "មានក្រិត្យវិន័យមួយដ៏ពុំអាចដកចេញបាន ដែលបានធ្វើនៅស្ថានសួគ៌មុនកំណើតលោកិយមកម្ល៉េះដែលគ្រប់ព្រះពរទាំងអស់ផ្អែកទៅលើ---ហើយកាលណាយើងបានព្រះពរណាមួយពីព្រះ នោះគឺដោយសារការគោរពដល់ក្រិត្យវិន័យនោះដែលព្រះពរនោះផ្អែកលើ"។ 1 ដង្វាយមួយភាគក្នុងដប់គឺជាបទបញ្ញត្តិមួយមកពីព្រះ ហើយនៅពេលយើងគោរពតាមច្បាប់របស់ទ្រង់ នោះទ្រង់ជាប់សេចក្តីសន្យាប្រទានពរដល់យើង។ ទោះជាក្មេងអាយុប្រាំពីរឆ្នាំក៏ដោយ នោះគឺជាអ្វីមួយដែលខ្ញុំអាចយល់ដឹង។ ប្រធានថូម៉ាស អេស ម៉នសុន នៅក្នុងការនិយាយ អំពីច្បាប់ទាំងឡាយរបស់ព្រះ លោកបានថ្លែងថាៈ "ការល្មើសនឹងច្បាប់ទាំងនោះ នោះយើងនឹងរងទុក្ខចំពោះ លទ្ធផលដ៏យូរអង្វែង ។ ការគោរពដល់ច្បាប់ទាំងនោះ នោះយើងនឹងច្រូតកាត់សេចក្តីអំណរជារៀងរហូត"។2

អ្នកនឹងចងចាំថា នៅពេលដែលពួកអ៊ីស្រាអែលត្រូវបានផ្ចាញ់ផ្ចាលចំពោះការកោងយករបស់ព្រះ រួចប្រជាជនបានសួរថា "តើយើងបានកោងយករបស់ទ្រង់ឯណា?" ចម្លើយបានឆ្លើយថា "គឺក្នុងដង្វាយមួយភាគក្នុងដប់ ហើយក្នុងដង្វាយលើកចុះឡើងនោះឯង"។ រួចហើយពួកអ៊ីស្រាអែល ត្រូវបានសន្យាថា បើពួកគេនឹងគោរពនូវច្បាប់ដង្វាយមួយភាគក្នុងដប់របស់ទ្រង់ នោះពួកគេនឹងត្រូវបានទទួលសិទ្ធិដើម្បីទទួលពរជ័យរបស់ទ្រង់។ ព្រះអម្ចាស់ មានបន្ទូលថា "ចូរ

នាំយកដង្វាយមួយភាគក្នុងដប់ទាំងអស់មកដាក់ក្នុងឃ្លាំងចុះ... ហើយល្បងលអញឥឡូវ បើអញមិន បើកទ្វារស្ថានសួគ៌ ដើម្បីចាក់ព្រះពរមកលើឯង ដែលនឹងគ្មានកន្លែងល្មមទុកបានទេ នេះហើយជាព្រះបន្ទូលរបស់ព្រះ យេហូវ៉ានៃពួកពលបរិវារ"។3

ព្រះអម្ចាស់បានសុំឱ្យពួកអ៊ីស្រាអែលឱ្យលទ្រង់ ឱ្យសាកល្បងទ្រង់ ឱ្យមានសេចក្តីជំនឿទៅលើទ្រង់ ដើម្បីទ្រង់នឹងអាចរក្សាការសន្យារបស់ទ្រង់ចំពោះពួកគេ។ បទបញ្ញត្តិដូចគ្នានោះ និងការសន្យាដូចគ្នានោះ គឺកំពុងតែមានប្រសិទ្ធភាពនៅសព្វថ្ងៃនេះ។ នៅពេលយើងរក្សាច្បាប់នៃដង្វាយមួយភាគក្នុងដប់ នោះការសន្យារបស់ព្រះអម្ចាស់ គឺពិតជា: ពរជ័យទាំងឡាយនឹងមានមកលើយើងទាំងខាងសាច់ឈាម និងខាងវិញ្ញាណ ស្របតាមព្រះតំរិះ និងពេលវេលារបស់ព្រះអម្ចាស់។

ភរិយារបស់ខ្ញុំ ឈ្មោះចូន និងខ្ញុំមានឱកាសរស់នៅក្នុងតំបន់ផ្សេងៗជាច្រើនក្នុងពិភពលោក ក្នុងចំណោមមនុស្សដ៏អស្ចារ្យដែលពឹងផ្អែកជាប្រចាំថ្ងៃទៅលើព្រះអម្ចាស់ សំរាប់សេចក្តីត្រូវការសំខាន់បំផុតខាងសាច់ឈាមរបស់ពួកគេ។ អ្នកទាំងឡាយដែលធ្វើដោយក្តីជំនឿក្នុងការបង់ដង្វាយមួយភាគក្នុងដប់របស់ពួកគេ បានថ្លែងទីបន្ទាល់ថាបង្អួច នៃស្ថានសួគ៌បានបើកចំពោះពួកគេ។ ខ្ញុំនៅចាំអំពីឪពុកដ៏ស្មោះត្រង់ម្នាក់នៅក្នុងប្រទេសហ្វីលីពីន បានប្រាប់អំពីការបង់ដង្វាយមួយភាគក្នុងដប់ដ៏តិចតួចរបស់លោក ទៅដល់ប៊ីស្សពក្នុងថ្ងៃអាទិត្យមួយ រួចហើយនាំកូនចៅរបស់គាត់ទៅផ្ទះពីព្រះវិហារវិញ ដោយដឹងយ៉ាងច្បាស់ថាពួកគេគ្មានម្ហូបអាហារសំរាប់ពួកគេឡើយ។ នៅពេលពួកគេកំពុងតែដើរតាមផ្លូវ ស្រាប់តែមានផ្លែឈើយ៉ាងធំមួយធ្លាក់ពីដើមវានៅចំពីមុខរបស់ពួកគេ។ ភ្លាមនោះ គាត់មើលទៅលើ ហើយអរគុណព្រះសំរាប់ការបើកបង្អួចស្ថានសួគ៌ ហើយប្រទានផ្លែឈើយ៉ាងធំនេះដល់គាត់ ដើម្បីគាត់ឱ្យកូនបរិភោគបាន។

យើងកំពុងតែរស់នៅក្នុងពេលដែលមានវិបត្តិសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ បើយើងក្រឡេកទៅមើលឆ្នាំមុនៗដែលកន្លងផុតទៅ យើងឃើញថា វាបានធ្លាប់ ហើយនឹងនៅបន្ត នូវពេលវេលានៃទំនាក់ទំនងភាពរុងរឿង និងពេលដែលមានភាពមិនពិតប្រាកដខាងហិរញ្ញវត្ថុ។ ប៉ុន្តែមិនថាឃើញថាខ្លួនយើងស្ថិតក្នុងកាលៈទេសៈណាទេ បើយើងបានបង់តាមកាតព្វកិច្ចរបស់យើងជាមុន ចំពោះព្រះអម្ចាស់ រួចហើយប្រើប្រាជ្ញា និងការវិនិច្ឆ័យល្អ នោះព្រះអម្ចាស់នឹងជួយយើងគ្រប់គ្រងធនធានទាំងឡាយដែលទ្រង់បានប្រទានដល់យើង។

ប្រធាន ហ៊ីប៊ើរ ចេ ក្រាន្ត បានថ្លែងថា "ខ្ញុំចង់និយាយទៅកាន់អ្នករាល់គ្នាថា បើអ្នកនឹងស្មោះត្រង់ចំពោះព្រះអម្ចាស់ ដោយការបង់ដង្វាយមួយភាគក្នុងដប់របស់អ្នក និងការគោរពបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះទ្រង់នឹងមិនត្រឹមតែប្រទានពរដល់អ្នកជាមួយនឹងពន្លឺ និងការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែអ្នកនឹងត្រូវបានប្រទានជាប្រាក់ និងជាកាក់ទាំងឡាយ ដែលអ្នកនឹងអាចសងបំណុលរបស់អ្នក ហើយព្រះអម្ចាស់នឹងចាក់ព្រះពរខាងសាច់ឈាមមកលើអ្នកយ៉ាងច្រើនដែលមិនអាចរកកន្លែងទុកបានឡើយ"។4

នៅក្នុងឆ្នាំ 1936 នៅពេលមានវិបត្តិដ៏ធំនៅក្នុងសហរដ្ឋ ជាពេលដែលមនុស្សជួបប្រទះនឹងការខ្វះខាត ក្នុងការបំពេញតំរូវការក្នុងជីវិត អែលឌើរ ចន អេ វីដសូ បានដាស់តឿនឱ្យពួកបរិសុទ្ធបង់ដង្វាយមួយភាគក្នុងដប់របស់ពួកគេ ដោយសារតែពរជ័យខាងវិញ្ញាណទាំងឡាយដែលពួកគេនឹងទទួល។ លោកមានប្រសាសន៍ថា: "ការគោរពប្រណិបត្តិដល់ច្បាប់ដង្វាយមួយភាគក្នុងដប់... នាំមកនូវសេចក្តីអំណរដ៏ជ្រាលជ្រៅ និងក្តីអំណរនៅខាងក្នុងខ្លួន... ដែលមិនអាចទទួលបានតាមផ្លូវណាទៀតឡើយ...។ គោលការណ៍ទាំងឡាយ នៃសេចក្តីពិតបានបង្ហាញឱ្យឃើញកាន់តែច្បាស់...។

ការអធិស្ឋានបានប្រែទៅជាការងាយស្រួលឡើង...។ ការយល់ដឹងខាងវិញ្ញាណ ត្រូវបានដុសខាត់ឡើង [ហើយ] ... មនុស្សកាន់តែប្រែក្លាយដូចជាព្រះវរបិតា ដែលគង់នៅឋានសួគ៌របស់ខ្លួន" ។5

ម្ដាយមួយរូបនៅឯភាគខាងលិចប្រទេសអាហ្វ្រិក បានចែកចាយនូវទីបន្ទាល់របស់គាត់អំពី ដង្វាយមួយភាគក្នុងដប់ ។ គាត់គឺជាឈ្មួញនៅទីផ្សារ ។ រាល់ថ្ងៃគាត់នឹងមកផ្ទះ រាប់យកប្រាក់ដង្វាយមួយភាគក្នុងដប់របស់គាត់ ហើយដាក់នៅកន្លែងពិសេសមួយ ។ បន្ទាប់មកនៅថ្ងៃអាទិត្យ គាត់នឹងយកប្រាក់នោះដោយស្មោះត្រង់ទៅកាន់ប៊ីស្សពរបស់គាត់ ។ គាត់បានចែកចាយជាមួយនឹងយើង អំពីអាជីវកម្មរបស់គាត់ថាវាបានរីកចំរើនប៉ុណ្ណា និងរបៀបដែលគ្រួសាររបស់គាត់ត្រូវបានប្រទានពរ ជាមួយនឹងសុខភាព និងកម្លាំង ហើយនឹងម្ហូបអាហារគ្រប់គ្រាន់ដើម្បីបរិភោគជាយ៉ាងណា ។ គាត់បាននិយាយទាំងទឹកភ្នែកថា "ប៉ុន្តែពរជ័យដែលធំបំផុត គឺថាកូនៗរបស់ខ្ញុំស្រឡាញ់ព្រះអម្ចាស់ ហើយយើងគឺជាគ្រួសារជារៀងរហូត" ។

ម្ដាយដ៏រាបទាបរូបនេះបានយល់ដឹងថាពរជ័យមួយនៃពរជ័យដ៏មហិមាទាំងឡាយ ក្នុងការធ្វើជាអ្នកបង់ដង្វាយមួយភាគក្នុងដប់ពេញលេញគឺជាឯកសិទ្ធិនៃការចូលក្នុងដំណាក់របស់ព្រះអម្ចាស់ ហើយចូលរួមនៅក្នុងការពិធីបរិសុទ្ធពិសិដ្ឋដែលអាចឱ្យក្រុមគ្រួសារនៅជាមួយគ្នាជារៀងរហូត ។

នៅពេលយើងបង់ដង្វាយមួយភាគក្នុងដប់របស់យើងដោយស្មោះត្រង់ នោះព្រះអម្ចាស់ប្រាកដនឹង "បើកបង្អួចឋានសួគ៌ ហើយចាក់មកលើយើងនូវពរជ័យដែលនឹងគ្មានកន្លែងនឹងទុកបានឡើយ" ។ ខ្ញុំចង់ឱ្យអ្នករាល់គ្នាម្នាក់ៗដឹង ជាពិសេសកូន និងចៅរបស់ខ្ញុំ ថាខ្ញុំដឹងក៏ដូចជាជីតារបស់ខ្ញុំដឹងផងដែរ ថាបើអ្នកបង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់ជានិច្ច នោះព្រះអម្ចាស់នឹងប្រទានពរដល់អ្នក ។ វានឹងក្លាយទៅជាការវិនិយោគដ៏ល្អបំផុត ដែលអ្នកមិនដែលធ្លាប់ធ្វើ ។ នូវការណ៍នេះ ខ្ញុំថ្លែងទីបន្ទាល់នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. គ. និង ស. 130:20 ។

2. *Pathways to Perfection: Discourses of Thomas S. Monson*(1973) ទំព័រ 126 ។

3. ម៉ាឡាគី 3:8, 10 ។

4. នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1898:16 ។

5. "Tithing Testimonies of Our Leaders" *Deseret News* ថ្ងៃទី 16 ខែ ឧសភា ឆ្នាំ 1936 Church Section ទំព័រទី 5 ។